**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៣០៥/ ០០៥ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីអាវុធគីមី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៥ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើត អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៧

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម (អ.ជ.អ.គ) ។

## ជំពូកទី ២

## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ. មានតួនាទី និងភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាពក្នុងការគ្រប់គ្រង ទប់ស្កាត់ការរីកសាយ អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម និងសារធាតុផ្សំដែលទាក់ទងនឹងការផលិតអាវុធគីមី ដើម្បីដាក់ជូន អ.ជ.អ.គ.
- អនុវត្តគោលនយោបាយ សារាចរ សេចក្តីណែនាំ បទបញ្ជា របស់អ.ជ.អ.គ និងរាជរដ្ឋាភិបាល
- អនុវត្តរាល់ខ្លឹមសារនៃសន្ធិសញ្ញា អនុសញ្ញា និងស្វែងយល់រាល់ការអនុវត្តរបស់អាជ្ញាធរជាតិនៃបណ្តាប្រទេសនានា ដែលជារដ្ឋភាគី
- ផ្សព្វផ្សាយ អប់រំ ធានាការអនុវត្ត និងតាមដាន ត្រួតពិនិត្យ រាល់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលរាជរដ្ឋាភិបាលបានសម្រេច
- រៀបចំលិខិតបទដ្ឋាននានា ទាក់ទងនឹងរាល់កិច្ចប្រជុំ ការចរចា ការចុះហត្ថលេខាលើសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង អនុស្សរណៈ ពិធីសារ កិច្ចសន្យា និងគម្រោងជំនួយទ្វេភាគី ពហុភាគី ដែលពាក់ព័ន្ធនឹងអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដើម្បីដាក់ជូន អ.ជ.អ.គ.
- ចាត់ចែងការងារឱ្យស្របទៅតាមវិធានការនានា ដែល អ.ជ.អ.គ. បានសម្រេចដើម្បី

គ្រប់គ្រង ត្រួតពិនិត្យ ទប់ស្កាត់ ចេញកំណត់ការនាំចេញ នាំចូល ការឆ្លងកាត់ ការស្តុកទុកសារធាតុគីមី និងជីវសាស្ត្រ និងសារធាតុទាក់ទងនឹងនុយក្លេអ៊ែរ និងវិទ្យុសកម្ម

- ប្រមូលពត៌មាន តាមដាន និងត្រួតពិនិត្យការងារនៃការទប់ស្កាត់ការរីកសាយអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម
- បូកសរុបលទ្ធផលនៃការនាំចេញ នាំចូល នូវរាល់សារធាតុគីមី ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- កៀរគរប្រភពធនធាន ជំនួយបច្ចេកទេស អាហារូបករណ៍ និងហិរញ្ញវត្ថុ ក្នុង និងក្រៅប្រទេស
- គ្រប់គ្រងរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងភស្តុភាររបស់ អ.ជ.អ.គ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល អ.ជ.អ.គ ប្រគល់ជូន ។

**មាត្រា ៣.-**

អគ្គលេខាធិការ មានតួនាទី និងភារកិច្ចដូចតទៅ ៖

- គ្រប់គ្រង ចាត់ចែង និងដឹកនាំការងារប្រចាំថ្ងៃ របស់អគ្គលេខាធិការដ្ឋាន នៃ អ.ជ.អ.គ.
- សម្របសម្រួលរាល់ការងារជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអង្គការអន្តរជាតិនានា
- រៀបចំកិច្ចប្រជុំរបស់ អ.ជ.អ.គ. និងកិច្ចប្រជុំនានា
- ត្រួតពិនិត្យ និងផ្តល់ការណែនាំក្នុងការប្រើប្រាស់ថវិកា និងសម្ភារៈ បរិក្ខារដែលផ្តល់ដោយរាជរដ្ឋាភិបាល និងជំនួយរបស់សហគមន៍ជាតិ និងអន្តរជាតិ ដល់សកម្មភាពទប់ស្កាត់ការរីកសាយអាវុធគីមី និងសារធាតុគីមី
- ស្នើសុំជ្រើសរើស តែងតាំង ឬដកចេញពីតំណែង នូវមន្ត្រី បុគ្គលិក របស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ.
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធាន អ.ជ.អ.គ. ប្រគល់ជូន ។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ត្រូវធ្វើការប្រជុំការងារយ៉ាងតិចពីរដងក្នុងមួយខែ តាមការអញ្ជើញ និងការណែនាំរបស់អគ្គលេខាធិការ ។

**មាត្រា ៥.-**

អគ្គលេខាធិការជាអាណាប័កផ្ទេរសិទ្ធិពីប្រធាន អ.ជ.អ.គ ដែលជាអាណាប័កដើមខ្សែ ។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន មានមន្ត្រីបំរើការងារមកពីក្របខណ្ឌកងយោធពលខេមរភូមិន្ទ ឬមន្ត្រីក្របខណ្ឌនៃមុខងារសាធារណៈ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋានអាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ មាននាយកដ្ឋាន និងវិទ្យាស្ថានចំណុះដូចតទៅ ៖

- នាយកដ្ឋាន រដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និង ភស្តុភារ
- នាយកដ្ឋាន គ្រប់គ្រងសារធាតុអាវុធគីមី
- នាយកដ្ឋាន ព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍
- នាយកដ្ឋាន ហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញ
- វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៩.-**

នាយកដ្ឋាន រដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងភស្តុភារ មានភារកិច្ចដូចតទៅ ៖

- សម្របសម្រួលផ្នែករដ្ឋបាលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំ និងគ្រប់គ្រងលិខិតបទដ្ឋាន ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការជាតិ អង្គការអន្តរជាតិ និងអគ្គលេខាធិការដ្ឋាន
- លើកសំណើគម្រោងផែនការរបស់នាយកដ្ឋានជំនាញនានាដាក់ជូនអគ្គលេខាធិការពិនិត្យ និងសម្រេច
- ទទួលរបាយការណ៍ពីនាយកដ្ឋានជំនាញ ដើម្បីបូកសរុប ដាក់ជូនអគ្គលេខាធិការពិនិត្យ
- ត្រួតពិនិត្យ និងបូកសរុបស្ថិតិបុគ្គលិក មន្ត្រីរាជការទូទាំង អគ្គលេខាធិការដ្ឋាន
- រៀបចំសំណុំលិខិតជ្រើសរើស តែងតាំង ឬដកចេញពីតំណែង នូវមន្ត្រី បុគ្គលិក របស់អគ្គលេខាធិការដ្ឋាន នៃ អ.ជ.អ.គ ដើម្បីជូនថ្នាក់លើសម្រេច
- រៀបចំសំណុំលិខិត ជូនរង្វាន់សរសើរ លិខិតសរសើរ ប័ណ្ណសរសើរ គ្រឿងឥស្សរិយយស

គោរម្យងារ ទៅតាមស្នាដៃបុគ្គលិក មន្ត្រីរាជការ និងស្ថាប័នចំណុះអគ្គលេខាធិការដ្ឋាន

- រៀបចំគម្រោងថវិកា ទិសដៅការងារសំរាប់អនុវត្តបន្ត និងសហការជាមួយនាយកដ្ឋានជំនាញដទៃទៀត ដើម្បីលើកគម្រោងសម្ភារៈ បរិក្ខារសំរាប់បំរើការនៅក្នុង អគ្គលេខាធិការដ្ឋាន
- ផ្តល់ការគាំទ្រផ្នែកភស្តុភារដល់អគ្គលេខាធិការដ្ឋាន
- រៀបចំ និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការ នៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃអ.ជ.អ.គ ប្រគល់ជូន។

**មាត្រា ១០.-**

នាយកដ្ឋាន គ្រប់គ្រងសារធាតុអាវុធគីមី មានភារកិច្ចដូចតទៅ ៖

- អនុវត្តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីបង្កើតការគ្រប់គ្រងក្នុងប្រទេស ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- សហការ ជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ អង្គភាពរដ្ឋ និងគ្រឹះស្ថាននានា ចាត់វិធានការដើម្បីគ្រប់គ្រង ត្រួតពិនិត្យ និងទប់ស្កាត់ ការចរាចរ នាំចេញ នាំចូល នូវសារធាតុ សំរាប់ផលិតអាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ស្រាវជ្រាវ រុករកនូវសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម នៅក្នុងភូមិសាស្ត្រប្រជាពលរដ្ឋ និងក្នុងកងកម្លាំងប្រដាប់អាវុធ
- ធ្វើផែនការ និងលើកគម្រោងទុកជាមុន ស្តីពីសកម្មភាពជួយសង្គ្រោះ និងបន្សាបជាតិពុលដែលបណ្តាលមកអំពីសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ក្នុងករណីកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃ អ.ជ.អ.គ ប្រគល់ជូន។

**មាត្រា ១១.-**

នាយកដ្ឋាន ព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍ មានភារកិច្ចដូចតទៅ ៖

- ស្រាវជ្រាវព័ត៌មាន ដើម្បីគ្រប់គ្រង ត្រួតពិនិត្យ ការធ្វើចរាចរសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

- ផ្សព្វផ្សាយ ធានាការអនុវត្ត ក្នុងការទប់ស្កាត់អោយបានទាន់ពេលវេលា នូវហេតុការណ៍ចៃដន្យ ដែលកើតមានឡើងដោយការរីកសាយអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- សហការជាមួយក្រសួង ស្ថាប័ននានា ដើម្បីប្រមូលព័ត៌មានស្តីពីការទប់ស្កាត់អាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- គ្រប់គ្រង ថែរក្សា និងត្រួតពិនិត្យ សំភារៈ បច្ចេកទេស និងឧបករណ៍ ដែលបានបំពាក់នៅតាមបណ្តាស្ថានីយ៍ត្រួតពិនិត្យទាំងអស់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃ អ.ជ.អ.គ ប្រគល់ជូន។

**មាត្រា ១២.-**

នាយកដ្ឋាន ហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញ មានភារកិច្ចដូចតទៅ ÷

- ធ្វើផែនការហ្វឹកហ្វឺនមុខជំនាញឯកទេស ស្តីពីបច្ចេកទេសការពារ សង្គ្រោះ ដែលបណ្តាលមកពីអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ធ្វើផែនការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបង្កើនសមត្ថភាពឯកទេសជំនាញ
- រៀបចំគំរោង បើកវគ្គសិក្សា វគ្គបំប៉ន វគ្គបណ្តុះបណ្តាល រយៈពេលខ្លី រយៈពេលវែង និងលើកគម្រោងស្នើសុំអាហារូបករណ៍ ទៅសិក្សានៅក្នុង និងក្រៅប្រទេស
- លើកកំពស់ការយល់ដឹង ដើម្បីស្វែងយល់ពីលក្ខណៈសង្គ្រាមអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ស្រាវជ្រាវ ចងក្រងឯកសារ បោះពុម្ព និងផ្សព្វផ្សាយ សំរាប់ធ្វើការទប់ស្កាត់ការរីករាលដាលអាវុធមហាប្រល័យ ដើម្បីធ្វើការហ្វឹកហ្វឺន
- លើកឡើងពីបទពិសោធន៍ ពាក់ព័ន្ធដល់ការសិក្សា អប់រំ និងការអនុវត្តការងារហ្វឹកហ្វឺនជំនាញឯកទេសអំពីអាវុធគីមី សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការនៃ អ.ជ.អ.គ ប្រគល់ជូន។

**មាត្រា ១៣.-**

វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី មានភារកិច្ចដូចតទៅ ÷

- ធ្វើការវិភាគ វាយតម្លៃ សារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម

- សហការរុករកសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ជាមួយនឹងមន្ទីរពិសោធន៍ក្នុង និងក្រៅប្រទេស
- គ្រប់គ្រងបណ្តាសម្ភារៈ និងឧបករណ៍ ដែលបានបំពាក់នៅមន្ទីរពិសោធន៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការនៃ អ.ជ.អ.គ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ប្រគល់ជូន។

**មាត្រា ១៤.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

វិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់។

រចនាសម្ព័ន្ធ នៃនាយកដ្ឋាននិមួយៗ និងវិទ្យាស្ថានស្រាវជ្រាវ និងពិសោធន៍សារធាតុអាវុធគីមី របស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.អ.គ ត្រូវកំណត់ដោយប្រកាសរបស់ អ.ជ.អ.គ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិអាវុធគីមី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១៦
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ២០០៧
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

អង្គការលេខ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

